# Living the Lotus 6

## Buddhism in Everyday Life

2025
VOL. 237



**2025 Northern California Cherry Blossom Festival**
**Rissho Kosei-kai Members in North America**
**Participate in the Grand Parade in San Francisco**








**Living the Lotus**
**Vol. 237 (June 2025)**

Senior Editor: Keiichi Akagawa
Editor: Sachi Mikawa
Copy Editor: Penn Setharin

*Living the Lotus* is published monthly
By Rissho Kosei-kai International,
Fumon Media Center, 2-7-1 Wada,
Suginami-ku, Tokyo 166-8537, Japan.
TEL: +81-3-5341-1124
FAX: +81-3-5341-1224
Email: living.the.lotus.rk-international@kosei-kai.or.jp


រីហ្សូកូសេកៃគឺជាអង្គការចលនាពុទ្ធសាសនាសកលមួយដែលមានពុទ្ធបរិស័ទ ជាច្រើនមានជំនឿលើគម្ពីព្រះសូត្រផ្កាឈូកសដែលជាព្រះសូត្ររបស់ព្រះពុទ្ធសាសនាមួយដ៏សំខាន់។ ពុទ្ធបរិស័ទទាំងនោះ បានខិតខំអនុវត្តការបង្រៀន របស់ព្រះបរមគ្រូនៃយើងទៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃដូចជា នៅកន្លែងការ ងារឬនៅក្នុងក្រុមគ្រួសាររបស់ពួកគាត់ជាដើម។ជាពិសេសគឺខំប្រឹងអនុវត្តធ្វើយ៉ាងណាអោយពិភពលោកទទួលបានសុខសន្តិភាព។

អង្គការរីហ្សូកូសេកៃ ត្រូវបានបង្កើតឡើងនៅឆ្នាំ 1983 ដោយ ស្ថាបនិក Nikkyo Niwano (1906-1999) និង, សហស្ថាបនាយិកា Myoko Naganuma (1889-1957) បច្ចុប្បន្នក្រោមការណែនាំពីលោកប្រធាន Nichiko Niwano សមាជិក រីហ្សូកូ សេកៃទាំងអស់ក្នុងនាមជាពុទ្ធបរិស័ទបានកំពុងប្រឹងប្រែងយ៉ាងសកម្មក្នុងការចែករំលែកព្រះធម៌និងចូលរួមសកម្មភាពសន្តិភាពទាំងក្នុងនិងក្រៅប្រទេសក្នុងកិច្ចសហការជាមួយមនុស្សគ្រប់មជ្ឈដ្ឋាន។

The title of this newsletter, *Living the Lotus—Buddhism in Everyday Life*, conveys our hope of striving to practice the teachings of the Lotus Sutra in daily life in an imperfect world to enrich and make our lives more worthwhile, like beautiful lotus flowers blooming in a muddy pond. This newsletter aims to help people around the world apply Buddhism more easily in their daily lives.

# អ្វីទៅដែលហៅថាកត្តញ្ញូកតវេទីចំពោះមាតាបិតា?

ដោយព្រះគ្រូនីវ៉ាណុ នីជិកុ
ព្រះប្រធានរីហ្ស៊ូកូសេកៃ



## មិនត្រូវស្អប់ មិនត្រូវឈ្លោះ

មានសុភាសិតជប៉ុនមួយចែងថា "នៅពេលដែលចង់សងគុណមាតាបិតាលោកទាំងពីរបានលាចាកលោកបាត់ទៅហើយ។ដល់ពេលនោះក៏មិនអាចយកភួយទៅតណ្តប់ឱ្យផ្នូរខ្មោចបានដែរ" ។

គឺជាទឹកចិត្តស្តាយក្រោយដោយមិនបានធ្វើជាកូនកត្តញ្ញូចំពោះមាតាបិតានៅពេលដែលអ្នកទាំងពីរនៅរស់រានមានជីវិត។ មានមនុស្សជាច្រើនដែលងក់ក្បាលទទួលស្គាល់ថា"ពិតជាដូច្នេះមែន" ។ ក៏ប៉ុន្តែក៏មិនមែនមានន័យថាមិនបាច់ចាំធ្វើអ្វីដូចពាក្យ"មិនអាចយកភួយទៅតណ្តប់ឱ្យផ្នូរខ្មោចបានដែរ" នោះឡើយ។

នៅលេខខែមុនខ្ញុំព្រះករុណាអាត្មាភាពបានសរសេរថានៅក្នុងមហាប្រវត្តិសាស្ត្រនៃជីវិតមានបន្តផ្ទាប់រហូតទៅដល់ការកកើតនៃចក្រវាលគឺជានិស្ស័យដែលមិនអាចខ្វះអ្វីមួយបានរួចហើ យយោងទៅតាមដំបងកាន់បន្តវេនរត់ប្រណាំ ងពីម្នាក់ទៅម្នាក់យើងតោងតែតណ្តឹងសួរហើយគិតខ្លួនឯងពីប្រភពនៃជីវិតរបស់យើងតាំងពីដូនតារហូតដល់មាតាបិតាយើងថាតើ  កត្តញ្ញូកត្តវេទីចំពោះឪពុកម្តាយជាអ្វីដើម្បីឱ្យបានចម្លើយថាតើឥឡូវនេះខ្លួនយើងអាចធ្វើអ្វីបានជាប្រយោជន៍ដល់អនាគតកាល ។

អក្សរចិនដែលបង្ហាញន័យ"កត្តញ្ញូ" គេសរសេរអក្សរដែលមានន័យថាមនុស្សចាស់ (老) ដាក់ពីលើអក្សរដែលមានន័យថាកូនក្មេង (子) គឺអក្សរ孝 (អានថាកូ) ដែលជាន័យថាតំណនិងការតផ្ទាប់គ្នានៃអ្វីដែលសំខាន់ពីមនុស្សចាស់ព្រឹទ្ធាចារ្យទៅកុមារដោយគ្មានការកាត់ផ្តាច់កណ្តាលទី។គឺជាការបង្ហាញពីការបង្រួបបង្រួមដោយការធ្វើឯកភាវូបនីយកម្ម។ដូច្នេះកត្តញ្ញូកតវេទីចំពោះមាតាបិតាគឺមានន័យធ្ងន់លើសពីការចិញ្ចឹមឬជូនមាតាបិតានូវអ្វីដែលគាត់ត្រូវការគ្រប់យ៉ាងទៅទៀត។

នៅក្នុងសៀវភៅ"ពាក្យបណ្តាំរបស់ខុងជឺ" មានសំណួរថាតើកត្តញ្ញូកតវេទីជាអ្វី?
ខុងជឺបានឆ្លើយយ៉ាងសាមញ្ញថា៖"មាតាបិតាតែងតែបារម្ភនឹងជម្ងឺកូន" (មាតាបិតាតែងតែព្រួយបារម្ភគ្រប់យ៉ាងពីកូនដូច្នេះកត្តញ្ញូកតវេទីចំពោះមាតាបិតាគឺកូនត្រូវតែសម្រួមកាយវាចាចិត្តធ្វើយ៉ាងណាកុំឱ្យគាត់បារម្ភ) ។
ពិតណាស់ថាចម្លើយនេះក៏សំខាន់ដែរ។បើយើ ងពិនិត្យមើលអក្សរចិនដែលមានន័យថាជម្ងឺ (疾) ទៅយើងនឹងឃើញថាក្រៅពីពាក្យថា  ជម្ងឺក៏អាចបកស្រាយបានថាស្អប់ ច្រណែន គុំកួន ធ្វើទុក្ខបុកម្នេញដែរ។ ព្រះគ្រូយ៉ាស៊ឺអ្វូកាម៉ាសាហ៊ីរ៉ូបានស្រាវជ្រាវរកឃើញថាពាក្យឬអក្សរ (疾) នេះវាដូចនឹងពាក្យថាវិវាទដែរ។

ដូច្នេះទំនាក់ទំនងមាតាបិតានិងកូនក៏ដូចជាទំនាក់ទំនងទាំងឡាយរវាងមនុស្សនិងមនុស្សដទៃដែរ។ ដើម្បីកុំឱ្យមានការផ្តាច់ទំនាក់ទំនងពីគ្នាដោយសារតែលោភៈបែបអត្តទត្តបុគ្គលនិងវិវាទគេតោងតែសម្រួមកាយវាចាចិត្ត។នេះហើយជាអ្វីដែលយើងអាចធ្វើបានជាប្រចាំដើម្បីឱ្យមាន កត្តញ្ញូកតវេទីចំពោះឪពុកម្តាយ។

## អកត្តញ្ញូដោយប្រព្រឹត្តបាណាតិបាតគឺការសម្លាប់សត្វមានជីវិត

ព្រះគ្រូងីយោគីដែលអ្នកស្រុកបានចាត់ទុកថាជាព្រះពោធិសត្វរស់ព្រោះលោកបានសង្គ្រោះមនុស្សក្រីក្រនិងនាំមនុស្សស្តុកទឹកដើម្បីកសិ កម្មបានសរសេរកំណាព្យមួយល្បះៈបក្សីព្រៃយំខ្ញុំស្រណោះឪ នឹកពេលឥឡូវបាត់ទាំងម៉ែផង។ គឺជាកំណាព្យដែលបង្ហាញទឹកចិត្តនឹករលឹកដ៏ជ្រាលជ្រៅចំពោះមាតាបិតាដែលបានចែកស្ថានទៅ។សម្លេងសត្វយំឮដូចជាសម្លេងដែលម្តាយឪពុកធ្លាប់ហៅខ្លួន។

ជាកំណាព្យមួយដែលចាក់ចុចបេះដូងអ្នកអាន។

យើងរាល់គ្នាតែងតែមានមនោសញ្ចេតនារំភើបនិងឈឺចាប់យ៉ាងនេះផងនិងជួនកាលមានអ្នកខ្លះភ្លេចគុណមាតាបិតាដែលបានបង្កើតខ្លួនមក អ្នកខ្លះទៀតខឹងម្តាយឪពុកដែលបង្កើតខ្លួនមកមិនស្អាត ឬក៏ឱ្យមានវាសនាមិនតាមបំណងខ្លួននិងកូនអកត្តញ្ញូដែលមិនដឹងគុណចំពោះជីវិតដែលបានទទួលក៏មាន។ព្រះគ្រូយោហ្គោ ស៊ូយកាំងនៃនិកាយសូតូស្ហូបានហៅទង្វើនេះថា"គឺជាបទល្មើសនឹងសីលបាណាតិបាតគឺការសម្លាប់សត្វមានជីវិត" ។

ព្រះគ្រូយោហ្គោ ស៊ូយកាំងអះអាងថាកាលណាយើងទាំងអស់គ្នាដែលរស់នៅយ៉ាងធម្មតានៅក្នុង "ចក្រវាលដែលមានជីវិតនៅពេញ" ជីវិតយើងម្នាក់ៗដែលមានធាតុជាព្រះពុទ្ធគឺជាជីវិតអស្ចារ្យ គ្មានជីវិតណាមួយដែលថាគ្មានន័យឬក៏អត្ថិភាពណាមួយដែលមិនគួរមាននោះទេនៅក្នុងលោកនេះ។ ការ " វិនិច្ឆ័យឬដាក់ពិន្ទុ" ឱ្យខ្លួនឯង និងទៅលើជីវិតខ្លួនឯង គឺជាការសម្លាប់ដោយមិនធ្វើស្វ័យត្រិះរិះពីជីវិតជាមូលដ្ឋាន ពោលគឺបំពានលើសីលមួយក្នុងចំណោមសីល៥ដែលពុទ្ធសាសនិកត្រូវតែគោរពគឺសីលដែលចែងថាបាណាតិបាតមិនសម្លាប់សត្វមានជីវិត។

ក្នុងន័យនេះ របៀបដែលយើងបង្ហាញកត្តញ្ញូតាធម៌ចំពោះមាតាបិតា គឺការបង្ក្រាបនូវអារម្មណ៍អត្តទត្ត ដូចជា កំហឹងនិងការមិនពេញចិត្ត តាមដែលអាចធ្វើទៅបាន មិនត្រូវឈ្លោះប្រកែកជាមួយអ្នកដទៃ ជឿជាក់លើធាតុជាព្រះពុទ្ធរបស់ខ្លួនយើង ហើយទទួលយកអ្វីៗថាជាស្នាដៃរបស់ព្រះពុទ្ធ (ឬសច្ចៈធម៌)។ លើសពីនេះ ដោយសារការងាររបស់ធម្មជាតិដែលមានមនុស្សផងដែរវាផ្អែកទៅលើគោលការណ៍នៃការរីកចម្រើនឥតឈប់ឈរ ការកែលម្អ និងការឆ្នៃប្រឌិត យើងក៏តោងតែមានទំនួលខុសត្រូវដ៏សំខាន់ក្នុងការ "បណ្តុះបណ្តាលមនុស្ស" ដែលត្រូវរែកពុនជំនាន់ក្រោយផងដែរហើយនេះក៏ជាវិធីមួយនៃការបង្ហាញកត្តញ្ញូកត្តវេទីចំពោះមាតាបិតានិងចំពោះខ្សែសង្វាក់នៃជីវិតដែលបន្តពីអតីតកាលទៅអនាគតកាល។

ហើយអ្វីដែលជាគន្លឹះគឺ "ភាពស្មោះត្រង់ និងក្តីមេត្តា" ដែលជាផ្នត់គំនិត និងអាកប្បកិរិយាដែលរួមបញ្ចូលនូវអ្វីដែលយើងបានពិភាក្សាកន្លងមក។ ការអាចលើកលែងទោស ទទួលយកអ្នកដទៃ មានភាពស្មោះត្រង់ មានចិត្តអាណិតអាសូរនិងមានសមានចិត្តចំពោះអ្នកដទៃ អាចមានឡើងដោយការអនុវត្តអ្វីទាំងនេះជារៀងរាល់ថ្ងៃ ដែលជាស្មារតីបុរាណជប៉ុនគឺស្មារតីយ៉ាម៉ាតូដ៏សំខាន់ពិតប្រាកដដែលយើងត្រូវតែបញ្ជូនបន្តទៅជំនាន់ក្រោយ។



# Rissho Kosei-kai International

## Make Every Encounter Matter



## A Global Buddhist Movement




Information about local Dharma centers

facebook

X

We welcome comments on our newsletter Living the Lotus: living.the.lotus.rk-international@kosei-kai.or.jp